www.kidworship.kr

# យ៉ាកុប ទី២

- 10th Story -



65Page

**Nar** អេសាវ បានស្អប់ដល់យ៉ាកុប ដោយព្រោះយ៉ាកុបបានយកសិទ្ធិជាកូនច្បងពីគាត់ និងបានយកពររបស់គាត់ទៀត។ ដោយព្រោះបញ្ហានេះ យ៉ាកុបក៏គ្មានជំរើសណា ផ្សេងក្រៅពីរត់គេចខ្លួនពីអេសាវឡើយ។ យ៉ាកុបបានរត់គេចទៅផ្ទះពូរបស់គាត់នៅឯខារ៉ាន។ នៅតាមផ្លូវយ៉ាកុបបានចាប់ផ្តើមមានចិត្តមិនស្រួលសោះ។



66Page

**Nar** ពេលព្រះអាទិត្យលិចហើយ យ៉ាកុបបានផ្អាកការធ្វើដំណើរទៅខារ៉ាន។ ពេលនោះ យ៉ាកុបបានយកថ្មមកកើយ ហើយគាត់គេងលក់នៅទីនោះទៅ។ ក្រោយមក យ៉ាកុបបានយល់សប្តិឃើញថា មានជណ្តើរមួយបញ្ឈរនៅលើផែនដី ចុងជណ្តើរនោះខ្ពស់រហូតដល់ឋានសួគ៌ ហើយមានទេវតារបស់ព្រះជាម្ចាស់ នាំគ្នាដែរចុះឡើងតាមជណ្តើរនោះ។ ពេលនោះ ព្រះជាម្ចាស់ ជាព្រះរបស់អ៊ីសាកបានស្ថិតនៅទីនោះហើយបាននិយាយទៅគាត់ថា

**God** យ៉ាកុបអើយ! យើងគឺជាព្រះអម្ចាស់។ យើងនិងអោយទឹកដីនេះដល់ឯងនិងពូជរបស់ឯង។ ពូជរបស់ឯង នឹងមានច្រើនដូចជាធូលីដី។ យើងនឹងនៅជាមួយឯង ហើយថែរក្សាគ្រប់ទីកន្លែងដែលឯងទៅ។



67Page

**Nar** យ៉ាកុបក៏បានភ្ញាក់ពីយល់សប្តិទាំងមានចិត្តភ្ញាក់ផ្អើល។ យល់សប្តិនេះ ពិតជាអស្ចារ្យមែន!

**Jacob** ព្រះអង្គម្ចាស់អើយ! ខ្ញុំសូមអរព្រះគុណដល់ទ្រង់។ ពេលយ៉ាកុបបានភ្ញាក់ពីគេង យ៉ាកុបក៏បានយកថ្ម ដែលគាត់បានកើយយកមកបញ្ឈរឡើង ធ្វើជាបង្គោលរួចក៏ចាក់ប្រេងពីលើថ្មនោះ។ យ៉ាកុបដាក់ឈ្មោះកន្លែងនោះថា បេត-អែល។ បន្ទាប់មក យ៉ាកុបក៏បានអរព្រះគុណដល់ព្រះជាម្ចាស់។

**Nar** ទីបំផុត យ៉ាកុបបានទៅដល់ផ្ទះពូរបស់គាត់ ឈ្មោះឡាបាន់។ នៅទីនោះគាត់បានឃើញរ៉ាជែល ដែលជាកូនស្រីរបស់ពូគាត់។ យ៉ាកុបក៏ចាប់ផ្តើមស្រលាញ់នាងភ្លាម នៅពេលដែលគាត់បានឃើញនាងនោះ។ ដូច្នេះ យ៉ាកុបក៏បាននិយាយទៅពូរបស់គាត់ថា



68Page

**Jacob** ពូអើយ! ខ្ញុំនិងនៅធ្វើការបម្រើពូរយៈពេលប្រាំពីរឆ្នាំ បើសិនជាពូឲ្យកូនស្រីពៅដែលឈ្មោះ រ៉ាជែលមកខ្ញុំ ធ្វើជាប្រពន្ធ។

**Nar** យ៉ាកុបក៏បានធ្វើការងារនៅក្នុងផ្ទះពូរបស់គាត់
អស់រយៈពេលប្រាំពីរឆ្នាំ។ តែដោយព្រោះយ៉ាកុបបានស្រលាញ់
រ៉ាជែលជាខ្លាំង ទើបរយៈពេលប្រាំពីរឆ្នាំនោះ មិនយូរទេ
សម្រាប់គាត់។

---


69Page

**Nar** យ៉ាកុបក៏បាននិយាយទៅឡាបាន់ជាពូរបស់គាត់ថា
**Jacob** ឥឡូវនេះ ប្រាំពីឆ្នាំបានកន្លងផុតហើយ ហេតុនេះ សូមពូអោយ
រ៉ាជែលមកធ្វើជាប្រពន្ធខ្ញុំមក។
**Nar** ប៉ុន្តែពូរបស់យ៉ាកុប បានយកកូនទី១របស់គាត់ ឈ្មោះថា
លេអា អោយធ្វើជាប្រពន្ធរបស់យ៉ាកុបជំនួសរ៉ាជែលទៅវិញ។
ឡាបាន់ មិនចង់អោយកូនប្អូន បានរៀបការមុនកូនបងឡើយ។
ដូច្នេះ ឡាបាន់ បានប្រាប់ទៅយ៉ាកុបថា


70Page

**Laban** បើសិនជាក្មួយធ្វើការអោយពូបានប្រាំពីរឆ្នាំទៀត នោះពូនិងអោយ
ក្មួយរៀបការជាមួយរ៉ាជែលជាមិនខាន។
**Nar** យ៉ាកុបក៏ធ្វើតាមសំដីរបស់ពូគាត់ ដោយបន្តធ្វើការនៅក្នុង
ផ្ទះពូរបស់គាត់ រយៈពេលប្រាំពីរឆ្នាំទៀត។ ពេលនោះ យ៉ាកុបបាន
ខិតខំធ្វើការណាស់។ ប្រាំពីឆ្នាំក្រោយមក យ៉ាកុបក៏បានរៀបការ
ជាមួយរ៉ាជែល អ្នកដែលគាត់ស្រលាញ់នោះទៅ។

---


71Page

យ៉ាកុបបានរៀបការជាមួយរ៉ាជែល ហើយនិងលេអា។ បន្ទាប់មក
**Nar** រ៉ាជែលនិងលេអា ក៏បានបង្កើតកូនជាច្រើនឲ្យយ៉ាកុប។ ពេលនោះ
យ៉ាកុបបានរស់នៅក្នុងផ្ទះពូរបស់គាត់។
យ៉ាកុបពិតជាខំធ្វើការណាស់។ គាត់បានមើលថែសត្វជាច្រើនមាន
ដូចជា ចៀម គោ និង អូដ្ឋ។ ដោយសារព្រះជាម្ចាស់បានអោយ
ពរដល់យ៉ាកុប ហេតុនេះទើបគាត់មានទ្រព្យសម្បត្តិជាច្រើន។